VSO



# សៀវភៅណែនាំ
# ស្តីពីការស្រាវជ្រាវប្រតិបត្តិ

វឌ្ឍនភាពអាចកើតមាន
លុះត្រាណាតែយើងធ្វើការរួមគ្នា

ខែធ្នូ ឆ្នាំ ២០១៩

សហភាពអឺរ៉ុប ស៊ុយអែត Sverige GLOBAL PARTNERSHIP for EDUCATION USAID ជំនួយពីពលរដ្ឋអាមេរិក unicef

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)

# មាតិកា

**បញ្ជីអក្សរកាត់** ........ ៤
**សេចក្តីផ្តើម** ........ ៥
**ជំពូក ១៖ គោលការណ៍នៃការស្រាវជ្រាវប្រតិបត្តិ** ........ ៦
**ជំពូក ២៖ ដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ** ........ ៧
ដំណាក់កាលទី ១៖ ការកំណត់បញ្ហា ........ ៨
ជំហានទី ១៖ បង្កើតក្រុមស្រាវជ្រាវប្រតិបត្តិ ........ ៨
ជំហានទី ២៖ ជ្រើសរើសប្រធានបទស្រាវជ្រាវ ........ ៨
ដំណាក់កាលទី ២៖ ការធ្វើផែនការ ........ ១០
ជំហានទី ១៖ ការបង្កើតលក្ខខណ្ឌយោង (ToR) ........ ១០
ជំហានទី ២៖ រៀបចំផែនការថវិកា និងការងារ ........ ១១
ជំហានទី ៣៖ ការត្រួតពិនិត្យឯកសារ និងការបង្កើតកម្រងសំណួរ ........ ១២
ដំណាក់កាលទី ៣៖ ការអនុវត្ត ........ ១៤
ជំហានទី ១៖ ការប្រមូលទិន្នន័យ ........ ១៤
ជំហានទី ២៖ ការវិភាគទិន្នន័យ ........ ១៥
ជំហានទី ៣៖ ការសរសេររបាយការណ៍ ........ ១៧
ជំហានទី ៤៖ សិក្ខាសាលាផ្សព្វផ្សាយ ........ ១៨
ដំណាក់កាលទី ៤៖ ការពិនិត្យតាមដាន និងការវាយតម្លៃ ........ ២០
**ជំពូក ៣៖ សេចក្តីសន្និដ្ឋាន** ........ ២១
ចំណុចសម្គាល់ពិសេសនៅក្នុងដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ ........ ២១
**ឧបសម្ព័ន្ធ ១ ទម្រង់របាយការណ៍គំរូ** ........ ២២
**ឯកសារយោង** ........ ២៣

# បញ្ជីអក្សរកាត់

| | |
|---|---|
| AOP | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| AR | ការស្រាវជ្រាវប្រតិបត្តិ |
| CDP | ភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព |
| DOE | ការិយាល័យអប់រំស្រុក |
| DoPo | នាយកដ្ឋានគោលនយោបាយ |
| EMA | ទីប្រឹក្សាផ្នែកគ្រប់គ្រងវិស័យអប់រំ |
| EMF | អ្នកសម្របសម្រួលផ្នែកគ្រប់គ្រងវិស័យអប់រំ |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| ESP | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| FGD | ការពិភាក្សាជាក្រុម |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| POE | មន្ទីរអប់រំខេត្ត |
| SMART | ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ដែលពាក់ព័ន្ធ និងមានពេលវេលាកំណត់ |
| SPSS | កម្មវិធីកញ្ចប់ស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម |
| ToR | លក្ខខណ្ឌយោង |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# សេចក្តីផ្តើម

ការស្រាវជ្រាវប្រតិបត្តិ (Action research) ត្រូវបានអនុវត្តនៅក្នុងបរិបទអប់រំជាការសាកសួរលក្ខណៈជាប្រព័ន្ធ ដែលតួអង្គនានាដូចជា គ្រូបង្រៀន នាយកសាលា និងអ្នកទទួលបន្ទុក ការងារ ផ្សេងទៀតដូចជា ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត ធ្វើឡើងតាមរយៈដំណើរការស្រាវជ្រាវ។គោលបំណងចម្បងគឺដើម្បីធ្វើការវាយតម្លៃសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុង ផ្នែកបង្រៀនគន្លងអាជីព ការធ្វើផែនការ និងការគ្រប់គ្រងសាលារៀន ឬស្ថាប័នថាតើសមិទ្ធផល ដែលខ្លួនសម្រេចបានកន្លងមកល្អប្រសើរកម្រិតណា ឬថាតើអ្វីខ្លះដែលដំណើរការល្អ ឬមិនល្អ ហើយថាតើចំណុចណាខ្លះដែលត្រូវធ្វើការកែលម្អ។ ការស្រាវជ្រាវប្រតិបត្តិ តម្រូវឱ្យមានការចូលរួមនិងការរួមចំណែកយ៉ាងសកម្មពីសំណាក់តួអង្គអប់រំក្នុងការផ្លាស់ប្តូរស្ថានភាព និងពង្រឹង គុណភាពផែនការយុទ្ធសាស្រ្តគោលនយោបាយ និងការអនុវត្តទើបកិច្ចការទាំងនេះអាចអនុវត្តបានដោយក្រុមធំឬក្រុមតូច ដោយមានជំនួយបន្ថែមពីអ្នកស្រាវជ្រាវជំនាញសំដៅឆ្ពោះទៅបង្កើន គុណភាព និងប្រសិទ្ធផលនៃលទ្ធផលស្រាវជ្រាវ។

សៀវភៅណែនាំនេះគឺត្រូវបានចងក្រងឡើងសម្រាប់ឱ្យគ្រូបង្រៀននាយកសាលានិងអ្នក ទទួលបន្ទុកដូចជា ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្តក៏ដូចជាមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ ដែលបម្រើការងារនៅក្នុងវិស័យអប់រំនៅថ្នាក់ក្រោមជាតិប្រើប្រាស់ផងដែរ។ សៀវភៅនេះអាចដាក់បញ្ចូល និងប្រើប្រាស់ជាឯកសារសម្រាប់ការស្រាវជ្រាវ ហើយជាមួយគ្នានេះក៏អាចបំពាក់បំប៉ន សមត្ថភាពរបស់មន្ត្រីក្នុងការបង្រៀនការធ្វើផែនការវិស័យអប់រំ និងការគ្រប់គ្រងឱ្យកាន់តែមាន គុណភាពល្អប្រសើរថែមមួយកម្រិតទៀត។ មានកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់គ្នាជាច្រើនដែលបានធ្វើឡើងជាមួយនឹងភាគីពាក់ព័ន្ធទាំង

ខាងក្នុង និងខាងក្រៅ ដូចជា ទីប្រឹក្សាគ្រប់គ្រងវិស័យអប់រំ (EMA) អ្នកសម្របសម្រួលការគ្រប់គ្រង វិស័យអប់រំ (EMF) និងបុគ្គលិកកម្មវិធីនៅក្នុងគម្រោង CDP នៃអង្គការ វីអេសអូ កម្ពុជាជាមួយនឹង មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) និងក្រសួងអប់រំយុវជន និងកីឡា (DoPo) ក្នុងគោលដៅធានានូវការអនុវត្តប្រកបដោយសង្គតិភាព ភាពប្រទាក់ក្រឡាគ្នានិងមានប្រសិទ្ធភាព។ ការស្រាវជ្រាវប្រតិបត្តិ គឺជាគោលគំនិតថ្មីមួយសម្រាប់កម្ពុជា ហេតុដូចនេះហើយ ទើបសៀវភៅណែនាំនេះ ត្រូវបានចងក្រងឡើងដោយបានមានការពិចារណាយ៉ាងល្អិតល្អន់ទៅលើ ការប្រើប្រាស់ភាសា និងវិធីសាស្រ្តដើម្បីឱ្យស្របគ្នាជាមួយនឹងបរិបទជាក់ស្តែង។

## តើការស្រាវជ្រាវប្រតិបត្តិគឺជាអ្វី?

ការស្រាវជ្រាវប្រតិបត្តិ (AR) គឺជាដំណើរការសម្រាប់កែលម្អប្រព័ន្ធអប់រំតាមរយៈការរួមបញ្ចូល និងការអនុញ្ញាតឱ្យបុគ្គលិកអប់រំ (គ្រូបង្រៀន នាយកសាលា) និងអ្នកពាក់ព័ន្ធ (ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងមន្ត្រីរដ្ឋាភិបាលនានា) ធ្វើការរួមគ្នាដើម្បីកែលម្អ សាលារបស់ខ្លួន។ ស្ថាប័ននិងផ្នែកវិជ្ជាជីវៈតាមរយៈការសិក្សាហ្មត់ចត់ ការប្រមូលទិន្នន័យ ការវិភាគល្អិតល្អន់ ការបង្កើនគុណភាពធ្វើផែនការ ការអនុវត្តនិងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពជាមួយនឹងការឆ្លុះបញ្ចាំងជាប្រចាំផងដែរ។

ការស្រាវជ្រាវប្រតិបត្តិ អាចហៅម្យ៉ាងទៀតថា "វដ្តនៃសកម្មភាព" ដោយសារតែជាធម្មតា វិធីសាស្រ្តស្រាវជ្រាវនេះគឺអនុវត្តតាមដំណើរការដដែលៗ ដូចជាការកំណត់រកបញ្ហាស្នូល ការបង្កើតផែនការស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ការដាក់បញ្ចូលលទ្ធផល រកឃើញទៅក្នុងផែនការ ដើម្បីអនុវត្ត និងការពិនិត្យតាមដាន និងការវាយតម្លៃសកម្មភាពហើយ បន្ទាប់មកទៀតអ្នកស្រាវជ្រាវនៅក្នុងវិស័យអប់រំ នឹងអនុវត្តដំណើរការនេះឡើងវិញជាថ្មីម្តងទៀត។ ដោយផ្អែកលើដំណើរការ និងវិធីសាស្រ្តនៃការស្រាវជ្រាវប្រតិបត្តិនេះ បុគ្គលិកអប់រំនិងអ្នក ពាក់ព័ន្ធសាលារៀន ឬស្ថាប័នជារឿយៗ ត្រូវបានផ្តល់សិទ្ធិអំណាច ក្នុងការធ្វើការផ្លាស់ប្តូរឱ្យត្រូវ ជាមួយនឹងថ្នាក់រៀន សាលារៀន ឬស្ថាប័នទាំងមូល (ឧទាហរណ៍ដូចជា កម្មវិធីសិក្សា កិច្ចតែងការ បង្រៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្រ្តវិស័យអប់រំ គោលនយោបាយវិស័យអប់រំ) ដើម្បីបង្កើនប្រសិទ្ធភាពផលប៉ះពាល់កម្រិតអតិបរមា។

សរុបជារួម សៀវភៅណែនាំនេះ អាចជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការពង្រឹង ប្រព័ន្ធអប់រំដោយសារតែសៀវភៅនេះមាននូវវិធីសាស្រ្តចម្បង និងក្របខ័ណ្ឌដែលធ្វើឱ្យអ្នក ស្រាវជ្រាវវិស័យអប់រំ អាចប្រមើលមើលអំពីបញ្ហាបានកាន់តែធំទូលាយ និងដោះស្រាយបញ្ហា ទាំងនោះដោយសមស្របតាមរយៈគោលគំនិតនិង ដំណោះស្រាយគ្រប់ជ្រុងជ្រោយដែលទទួលបានតាមរយៈទិន្នន័យអាចទុកចិត្តបានពីកិច្ចការស្រាវជ្រាវដែលបានធ្វើឡើង។ ការស្រាវជ្រាវ ប្រតិបត្តិមក៏អាចប្រើប្រាស់ដើម្បីបង្កើនសំឡេងការចូលរួម និងកិច្ចសន្ទនារបស់សហគមន៍ ក្នុងការកែលម្អវិស័យអប់រំនៅកម្រិតមូលដ្ឋានរបស់ពួកគាត់បានផងដែរ។

# ជំពូក ១៖ គោលការណ៍នៃការស្រាវជ្រាវប្រតិបត្តិ

ជាគោលការណ៍ ការស្រាវជ្រាវប្រតិបត្តិ ត្រូវបានបែងចែកជា ៤ ប្រភេទផ្សេងៗគ្នា ដែលមានគោលដៅបង្កើនវិសាលភាពនៃការផ្លាស់ប្តូរ៖

១. ***ការស្រាវជ្រាវលក្ខណៈបុគ្គល៖*** ការស្រាវជ្រាវប្រភេទនេះសំដៅដល់ការស្រាវជ្រាវដែលធ្វើឡើងដោយបុគ្គលិកអប់រំតែម្នាក់ (គ្រូបង្រៀន ឬនាយកសាលា) ឬជាមន្ត្រី (ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត)។ ការស្រាវជ្រាវប្រភេទនេះត្រូវបានធ្វើឡើងគឺដើម្បីធ្វើការវិភាគទៅលើកិច្ចការជាក់លាក់មួយ។ ឧទាហរណ៍ គ្រូបង្រៀន/នាយកសាលាគិតគូរអំពីសកម្មភាពការងារជាក្រុមនៅក្នុងថ្នាក់រៀន ដែលអាចជួយបង្កើនលទ្ធផលសិក្សារបស់សិស្ស។ បន្ទាប់មកទៀត ពួកគាត់អាចចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវដោយខ្លួនឯងដើម្បីប្រមូលព័ត៌មាន។ បន្ទាប់ពីពួកគាត់ទទួលបានលទ្ធផលហើយ ពួកគាត់អាចធ្វើការលុបចោលនូវសកម្មភាពមិនបានការមួយចំនួន ហើយបន្ទាប់មក ជំនួសដោយវិធីសាស្ត្របង្រៀនថ្មីដោយផ្អែកទៅលើលទ្ធផលរកឃើញ និងអនុសាសន៍សំខាន់ៗ។

២. ***ការស្រាវជ្រាវបែបសហការ៖*** ការស្រាវជ្រាវប្រភេទនេះគឺជាការស្រាវជ្រាវជាក្រុម។ ជារឿយៗការស្រាវជ្រាវបែបសហការនេះគឺមានមនុស្សច្រើនជាងម្នាក់ចូលរួម ហើយពួកគាត់អាចមកពីការិយាល័យ/ថ្នាក់ផ្សេងៗគ្នានៅតាមសាលារៀនណាមួយ ប៉ុន្តែពួកគាត់ត្រូវតែមានចំណាប់អារម្មណ៍រួមចំពោះប្រធានបទជាក់លាក់ណាមួយដែលត្រូវធ្វើការសិក្សាស្រាវជ្រាវ។ ជារឿយៗ ការស្រាវជ្រាវប្រភេទនេះរួមមាន គ្រូបង្រៀន និងនាយកសាលាដែលធ្វើការរួមគ្នា និងអាចផ្តល់អត្ថប្រយោជន៍ច្រើនជាងការស្រាវជ្រាវលក្ខណៈបុគ្គល។

៣. ***ការស្រាវជ្រាវទិដ្ឋភាពរួមសាលារៀន៖*** នៅពេលដែលការស្រាវជ្រាវត្រូវបានធ្វើឡើងសម្រាប់សាលាទាំងមូល គេហៅថា ជាការស្រាវជ្រាវទិដ្ឋភាពរួមសាលារៀន។ ការធ្វើ ការស្រាវជ្រាវប្រតិបត្តិប្រភេទនេះ សាលាប្រហែលជាមានការព្រួយបារម្ភអំពីបញ្ហានៅក្នុងសាលាទាំងមូល។ បញ្ហានេះអាចជាការខ្វះខាតនូវការចូលរួមរបស់អាណាព្យាបាលរបស់សិស្ស ឬអាចជាការស្រាវជ្រាវដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សតាមមុខវិជ្ជាជាក់លាក់ណាមួយ។ តាមរយៈការស្រាវជ្រាវនេះ បុគ្គលិកទាំងអស់ធ្វើការរួមគ្នាដើម្បីសិក្សាអំពីបញ្ហា អនុវត្តការផ្លាស់ប្តូរ និងកែតម្រូវកំហុសឆ្គង ឬដោយសង្ឃឹមថា នឹងបង្កើនលទ្ធផលសិក្សារបស់សិស្សឱ្យកាន់តែល្អប្រសើរឡើង។

៤. ***ការស្រាវជ្រាវថ្នាក់ស្រុក/ខេត្ត៖*** ការស្រាវជ្រាវទូទាំងស្រុក/ខេត្តត្រូវបានធ្វើនៅក្នុងស្រុក ឬខេត្តទាំងមូល។ ការធ្វើ ការស្រាវជ្រាវប្រតិបត្តិ ប្រភេទនេះ គឺភាគច្រើនផ្អែកទៅលើសហគមន៍ជាងការស្រាវជ្រាវប្រភេទផ្សេងទៀត ដោយសារតែការស្រាវជ្រាវនេះកំណត់គោលដៅទៅលើប្រជាជននៅក្នុងសហគមន៍ (ឪពុកម្តាយសិស្ស គណៈកម្មាធិការទ្រទ្រង់សាលា និងអាជ្ញាធរមូលដ្ឋាន) ជាជាងការជ្រើសរើសសិស្ស ឬបុគ្គលិកអប់រំធ្វើជាអ្នកឆ្លើយតប។ ការស្រាវជ្រាវប្រភេទនេះ ក៏អាចប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហារបស់អង្គភាពនៅក្នុងស្រុក ឬខេត្តទាំងមូលបានផងដែរ។ ការស្រាវជ្រាវនេះគឺកំពុងតែអនុវត្តនៅតាមបណ្តាខេត្ត និងស្រុកនានានៃគម្រោងភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព ហើយការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត ត្រូវបានបង្កើតឡើងដើម្បីធ្វើការងារជាក្រុមស្រាវជ្រាវប្រតិបត្តិ (AR) ដើម្បីស្វែងរក និងដោះស្រាយបញ្ហានៅតាមទីតាំងរៀងៗខ្លួន។

**ដោយផ្អែកទៅលើរចនាបថនៃការស្រាវជ្រាវប្រតិបត្តិនីមួយៗ ការផ្លាស់ប្តូរបីកម្រិតត្រូវបាន បង្កើតឡើង៖**

(១) ***ការប្រែប្រួលលក្ខណៈបុគ្គលម្នាក់ៗ៖*** សំដៅដល់ស្វ័យប្រែប្រួលរបស់បុគ្គលម្នាក់ៗដែលបានធ្វើការស្រាវជ្រាវ។ បុគ្គលរូបនេះគឺកំពុងតែស្វែងរកការយល់ដឹងកាន់តែល្អប្រសើរអំពីឥទ្ធិពលនៃសកម្មភាពរបស់ខ្លួន និងដើម្បីបង្កើនប្រសិទ្ធភាពការងារនៅក្នុងជីវិតផ្ទាល់ខ្លួន។

(២) ***ការប្រែប្រួលក្នុងថ្នាក់រៀននិងសាលារៀន៖*** កម្រិតទីពីរគឺជាដំណើរការរួមនៃការយល់ដឹងអំពីបញ្ហានិងផលប៉ះពាល់របស់បញ្ហា ដើម្បីឈាន ទៅដល់ការបង្កើតឱ្យមានការប្រែប្រួល និងការកែតម្រូវកំហុស ឬលទ្ធផលសិក្សានៅក្នុងថ្នាក់ ឬសាលារៀនទាំងមូល។

(៣) ***ការប្រែប្រួលរបស់សហគមន៍និងអង្គភាព៖*** ការស្រាវជ្រាវប្រតិបត្តិ ធ្វើឡើងសម្រាប់ បង្កើនសំឡេងរបស់សហគមន៍ក្នុងការដោះស្រាយបញ្ហារបស់សហគមន៍ ឬអង្គភាពនៅទូទាំងស្រុក/ខេត្តដើម្បីសម្រេចបាននូវគោលដៅ ឬ ចក្ខុវិស័យកម្មវិធីនៃ អង្គភាពមួយ។

# ជំពូក ២៖ ដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ

ការស្រាវជ្រាវប្រតិបត្តិមាន៤ដំណាក់កាល ហើយដំណាក់កាលនីមួយៗមានជំហានដូចខាងក្រោម។ ដ្យាក្រាមខាងក្រោមនេះបង្ហាញពីវដ្តនៃ ការស្រាវជ្រាវប្រតិបត្តិ។

ដ្យាក្រាមដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ



# ជំណាក់កាលទី ១៖
# ការកំណត់បញ្ហា

### ជំហានទី ១៖ បង្កើតក្រុមស្រាវជ្រាវប្រតិបត្តិ

ការស្រាវជ្រាវលក្ខណៈបុគ្គលមិនមែនជាការស្រាវជ្រាវមានភាពសមស្របគ្រប់ពេលនោះទេ។ ប្រសិនបើការស្រាវជ្រាវបែបនេះមិនសមស្របយើងត្រូវតែគិតគូរការបង្កើតក្រុមមួយ។ ក្រុមនោះអាចជាក្រុមស្រាវជ្រាវរួមគ្នាឬការស្រាវជ្រាវទូទាំងសាលាឬការស្រាវជ្រាវទូទាំង ស្រុក/ខេត្ត ដូច្នេះការជ្រើសរើសសមាជិកក្រុមគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។

ក្រុមស្រាវជ្រាវរួមត្រូវការសមាជិកយ៉ាងតិចបំផុត ២នាក់មកពីការិយាល័យ/ថ្នាក់ផ្សេងគ្នា នៅក្នុង សាលារៀនដើម្បីធ្វើការស៊ើបអង្កេតទៅលើប្រធានបទ ឬបញ្ហាជាក់លាក់ណាមួយ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីកែលម្អគន្លងអាជីពឬពិនិត្យមើលអំពីសមិទ្ធផលរបស់ខ្លួន។ ទំហំ ក្រុមនេះ មិនគួរមានសមាជិកលើសពី ៣ នាក់ឡើយ។

ចំណែកឯការស្រាវជ្រាវទូទាំងសាលារៀនវិញ ក្រុមស្រាវជ្រាវគឺមានទំហំធំជាងការស្រាវជ្រាវ រួមបន្តិចដោយសារតែវិសាលភាពនៃការស្រាវជ្រាវនេះ គឺគ្របដណ្ដប់ទៅលើសាលារៀនទាំងមូលតែម្ដង។ ដូចនេះក្រុមស្រាវជ្រាវនេះគួរតែមានសមាជិកចាប់ពី៣ទៅ៥នាក់ ម្នាក់ដើម្បី ធ្វើការបែងចែក តួនាទីនិងទំនួលខុសត្រូវអមជាមួយនឹងគោលគំនិត និងអនុសាសន៍គ្រប់ជ្រុងជ្រោយផងដែរ។

សម្រាប់ការស្រាវជ្រាវទូទាំងស្រុក/ខេត្តវិញបុគ្គលិកមកពីសាលារៀននីមួយៗនៅក្នុងស្រុក/ខេត្តនឹងសហការគ្នាក្នុងការស្រាវជ្រាវទៅលើបញ្ហាណាមួយ និងស្វែងរកវិធីសាស្ត្រធ្វើការកែលម្អស្ថានភាពបច្ចុប្បន្នដូចនេះក្រុមស្រាវជ្រាវគួរតែមានសមាជិកយ៉ាងតិចបំផុតចាប់ពី៦-១០នាក់ ទើបអាចគ្របដណ្ដប់បានគ្រប់ចំណុចគោលដៅ ឬស្រុក ឬខេត្តទាំងមូលបាន។

ជាធម្មតានៅក្នុងក្រុមស្រាវជ្រាវគឺមានតួនាទីចំនួន៣៖ ប្រធានក្រុម អ្នកសម្របសម្រួល និងអ្នកកត់ត្រា។ ប្រធានក្រុមគឺជាអ្នកទទួលខុសត្រូវក្នុងការធ្វើផែនការស្រាវជ្រាវ ការគ្រប់គ្រងក្រុម និងការសម្របសម្រួលកិច្ចការទាំងមូល ទើបដំណើរការស្រាវជ្រាវអាចប្រព្រឹត្តទៅដោយរលូនបាន និងមានប្រសិទ្ធភាពខ្ពស់។ អ្នកសម្របសម្រួល គឺជាបុគ្គលដែលធ្វើការសម្ភាសន៍អ្នកឆ្លើយតប និងសម្របសម្រួលកិច្ចពិភាក្សា/កិច្ចពិគ្រោះយោបល់ហើយអ្នកកត់ត្រាគឺជាបុគ្គលដែលកត់ត្រា នូវរាល់ចម្លើយរបស់អ្នកចូលរួមទាំងអស់ព្រមទាំងជួយធ្វើការអ្នកសម្របសម្រួលក្នុងករណីមានការរំខានពីខាងក្រៅ ឬនៅពេលណាដែលចាំបាច់ត្រូវធ្វើការបញ្ជាក់បន្ថែមណាមួយ។

### ជំហានទី ២៖ ជ្រើសរើសប្រធានបទស្រាវជ្រាវ

ការជ្រើសរើសប្រធានបទគឺជាជំហានដំបូងគេនៅក្នុងដំណើរការនេះ ហើយវាក៏មានសារៈ សំខាន់ខ្លាំងបំផុតផងដែរ។ ការជ្រើសរើសប្រធានបទស្រាវជ្រាវចាប់ផ្ដើមជាមួយនឹងចំណុចដូចខាងក្រោម៖

- ***ការបំផុសបញ្ហា៖*** ជាការបំផុសបញ្ហាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយបន្ទាប់មកយក ចិត្តទុកដាក់ភ្លាមៗ ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីបញ្ហានីមួយៗដែលបានកំណត់ចេញពីទស្សនៈផ្ទាល់ខ្លួនឬទស្សនៈ របស់អង្គភាពដោយមានគោលបំណងដើម្បីកំណត់អាទិភាព និងជ្រើសរើសបញ្ហាណាដែលល្អប្រសើរជាងគេបំផុតសម្រាប់យកមកធ្វើការសិក្សា។
- ***បង្រួមបញ្ហាឱ្យតូច៖*** បន្ទាប់ពីបានធ្វើការបំផុសបញ្ហានានារួចហើយអ្នកស្រាវជ្រាវត្រូវតែ បង្រួមបញ្ហាទាំងនោះឱ្យកាន់រួមតូចដោយប្រើការវិភាគមែកធាងបញ្ហា ដោយសារតែការវិភាគ នេះអាចជួយអ្នកស្រាវជ្រាវក្នុងការកំណត់ និងជ្រើសរើសប្រធានបទដោយប្រសិទ្ធភាព នៅក្នុងបរិបទបច្ចុប្បន្នរបស់ខ្លួន ដោយផ្អែកទៅលើដើមចម និងឥទ្ធិពលបញ្ហាទាំងអស់នោះ។ ដើម្បីអាចកំណត់រកឃើញឥទ្ធិពល និងដើមចមបញ្ហា អ្នកស្រាវជ្រាវត្រូវតែសួរសំណួរថា "ហេតុអ្វីបានជាបញ្ហានេះកើតឡើង ហើយមានអ្វីខ្លះជាដើមចមធ្វើឱ្យបញ្ហាទាំងនោះកើតឡើង? តើលទ្ធផលឬផលវិបាកនៃបញ្ហានេះមានអ្វីខ្លះ?" ដូច្នេះសូមមើលការវិភាគមែកធាង នៃបញ្ហានៅ ក្នុងប្រអប់ខាងក្រោម៖




- ***ការជ្រើសរើសប្រធានបទ៖*** កំណត់បញ្ហាដែលមានសារៈសំខាន់បំផុត មានសារៈប្រយោជន៍បំផុត ឬមិនសូវពិបាកដោះស្រាយ ក៏ដូចជា ដោយផ្អែកទៅលើថវិកា និងរយៈពេលដែលមាន។ ចំណុចទាំងនេះគឺជាចំណុចអាទិភាពសម្រាប់ការស្រាវជ្រាវប្រតិបត្តិ។ កំណត់នូវឥទ្ធិពលដែលបង្កជាបញ្ហាខ្លាំងជាងគេបំផុតដល់មនុស្សដែលអាចជាចំណុចដែលយើងចាប់អារម្មណ៍ចង់ស្វែងយល់អំពីបរិយាបន្នឱ្យបានកាន់តែប្រសើរ ហើយដូចនេះ យើងអាចជ្រើសរើសបញ្ហា ជាពិសេស បញ្ហា កុមារ ឬសិស្សងាយរងគ្រោះ ដែលចូលរៀននៅក្នុងសាលារៀន ឬស្ថាប័នរបស់យើង។ នៅក្នុងអំឡុងពេលជ្រើសរើសប្រធានបទ អ្នកស្រាវជ្រាវត្រូវតែយកចិត្តទុកដាក់ខ្ពស់ទៅលើដើមចម និងផលប៉ះពាល់នៃបញ្ហាស្នូលដែលពួកគាត់គិតថាមានសារៈសំខាន់បំផុត និងអាចប៉ះពាល់ទៅលើសាលារៀន និងស្ថាប័នរបស់ខ្លួន។

# ដំណាក់កាលទី ២ ៖ ការធ្វើផែនការ

### ជំហានទី ១៖ ការបង្កើតលក្ខខណ្ឌយោង (ToR)

លក្ខខណ្ឌយោង (ToR) គឺជាផែនការស្រាវជ្រាវ ដែលរួមបញ្ចូលនូវសារតារនៃការស្រាវជ្រាវការកំណត់បញ្ហា គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ វិធីសាស្ត្រ និងបច្ចេកទេសស្រាវជ្រាវ។លក្ខខណ្ឌយោងនេះក៏មានរៀបរាប់លម្អិតនូវវិសាលភាព និងសំណាកគំរូ ក៏ដូចជា រយៈពេលស្រាវជ្រាវផងដែរ។ សូមមើលព័ត៌មានខាងក្រោម៖

- ***សារតារនៃបរិបទ៖*** ផ្នែកនេះមានចែងនូវសារតារសម្រាប់ការស្រាវជ្រាវជាមួយនឹងកត្តាមូលដ្ឋានដែលជះឥទ្ធិពលទៅលើវិស័យអប់រំ (បែងចែកតាមលក្ខណៈប្រជាសាស្ត្រភូមិសាស្ត្រហេដ្ឋារចនាសម្ព័ន្ធវិសមភាពយេនឌ័រ ស្ថានភាពនៃការរើសអើងស្ថានភាពសេដ្ឋកិច្ចក្នុងមូលដ្ឋានអត្រាភាពក្រីក្ររបាំងភាសា ក្នុងមូលដ្ឋាន ។ល។)។
- ***ការកំណត់បញ្ហា៖*** គឺជាសេចក្តីពណ៌នាយ៉ាងសង្ខេបអំពីបញ្ហាដែលត្រូវដោះស្រាយ ឬស្ថានភាពដែលត្រូវកែលម្អ។ ការកំណត់បញ្ហាគួរតែមានរៀបរាប់ឱ្យបានលម្អិតអំពីបញ្ហា និងគោលដៅជាក់លាក់ដើម្បី ឆ្លើយតបទៅនឹងបញ្ហាឬគោលបំណងនៃការស្រាវជ្រាវ។ជារួមការកំណត់បញ្ហា ត្រូវតែមាន ភាពច្បាស់លាស់ សង្ខេបខ្លី មានលក្ខណៈប្រាកដនិយម និងពាក់ព័ន្ធនឹងបរិបទ។
- ***គោលបំណង៖*** ជាសេចក្តីថ្លែងដែលរៀបរាប់អំពីចំណុចដែលកិច្ចការស្រាវជ្រាវត្រូវស្វែងរកឱ្យឃើញ និងស្វែងរកចម្លើយសម្រាប់ប្រធានបទស្រាវជ្រាវ។ គោលបំណងនៃការស្រាវជ្រាវអាចមានច្រើន តែបើច្រើនពេកគឺអាចធ្វើឱ្យការស្រាវជ្រាវកាន់តែស្មុគស្មាញខ្លាំងទៅវិញ។
- ***សំណួរស្រាវជ្រាវ៖*** ជាសំណួរស្នូលដែលសួរដើម្បីស្វែងរកនូវព័ត៌មានដែលអាចឆ្លើយទៅគោលបំណងនៃការស្រាវជ្រាវ។
- ***វិធីសាស្ត្រស្រាវជ្រាវ៖*** អ្នកស្រាវជ្រាវត្រូវតែគិតគូរឱ្យបានល្អិតល្អន់មុននឹងសម្រេចចិត្តជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ពីព្រោះការជ្រើសរើសនេះអាចមានឥទ្ធិពលលើលទ្ធផលនៃការស្រាវជ្រាវនៅចុងបញ្ចប់។



- **វិធីសាស្ត្រស្រាវជ្រាវប្រតិបត្តិ៖** ការស្រាវជ្រាវប្រតិបត្តិអាចទទួលបានផលពីវិធីសាស្ត្រផ្សេងៗគ្នាជាច្រើនរហូតដល់ការសួរសំណួរច្បាស់លាស់ ដែលរួមបញ្ចូលទាំងវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។ ដូចនេះអ្នកស្រាវជ្រាវត្រូវតែគិតគូរដោយយកចិត្តទុកដាក់ថា តើគួរប្រើប្រាស់វិធីសាស្ត្រមួយណាដើម្បីទទួលបាននូវទិន្នន័យដែលអាចទុកចិត្តបាន។ មានវិធីសាស្ត្រ ស្រាវជ្រាវស្ទួលចំនួន២ដែលគេប្រើប្រាស់ក្នុងការស្រាវជ្រាវហើយវិធីសាស្ត្រទាំងពីរនេះមាននិយមន័យខុសគ្នាដូចខាងក្រោម៖
    - **ការស្រាវជ្រាវបែបគុណវិស័យ** ពឹងផ្អែកទៅលើការពណ៌នាផ្ទាល់មាត់យ៉ាងលម្អិតនៃបាតុភូត គំនិតយោបល់ទស្សនៈឥរិយាបថនិងផលវិបាក។ ការស្រាវជ្រាវបែបនេះមិនតម្រូវឱ្យមានទិន្នន័យជាតួលេខ ឬក៏ភាគរយនោះទេ ប៉ុន្តែវាមានគោលដៅពណ៌នាអំពីមូលហេតុ និងរបៀបដែលបញ្ហាណាមួយកើតឡើង ព្រមទាំងព្យាករណ៍អំពីនិន្នាការអនាគតផងដែរ។ ជាធម្មតា ចំនួនសំណួរ ទំហំសំណាកគំរូ និងចំនួនអ្នកឆ្លើយតបគឺមានចំនួនតិច ដែលធ្វើឱ្យអ្នកស្រាវជ្រាវអាចវិភាគទិន្នន័យ/ព័ត៌មានបានយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធផល។
    - **ការស្រាវជ្រាវបែបបរិមាណវិស័យ** ពឹងផ្អែកទៅលើទិន្នន័យស្ថិតិដែលមានគោលដៅពន្យល់អំពីចំនួនដងដែលបញ្ហាទាំងនោះបានកើតឡើង ដូចនេះការស្រាវជ្រាវត្រូវតែបង្ហាញជាតួលេខ និងភាគរយ។ បន្ទាប់មក ជាធម្មតា ការស្រាវជ្រាវនេះបង្ហាញជាដ្យាក្រាមឬក្រាហ្វិក។ ការស្រាវជ្រាវបែបនេះត្រូវបានពិចារណា ដោយអ្នកស្រាវជ្រាវដើម្បីឱ្យមានភាពងាយស្រួលក្នុងការវិភាគ និងពន្យល់ពីបាតុភូត និងផលវិបាក។
- **បច្ចេកទេសប្រមូលទិន្នន័យ** សំដៅដល់វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ។ ការជ្រើសរើស បច្ចេកទេសត្រឹមត្រូវអាចមានឥទ្ធិពលទៅលើលទ្ធផលរបស់អ្នកស្រាវជ្រាវ។ អ្នកស្រាវជ្រាវអាចជ្រើសរើសបច្ចេកទេសតែមួយឬបច្ចេកទេសចម្រុះបញ្ចូលគ្នា។ បច្ចេកទេសក្នុងការប្រមូលទិន្នន័យគឺមានចំនួន ៤ បច្ចេកទេសរួមមានដូចជា៖
    - **កម្រងសំណួរ៖** ជាឧបករណ៍ដាច់ដោយឡែកតែឯង ដែលប្រើប្រាស់ក្នុងការប្រមូល ទិន្នន័យនៅពេលដែលសំណួរទាំងអស់ត្រូវបានបង្កើតឡើង ហើយជូនកាល ចម្លើយសំណួរក៏ត្រូវបានរៀបចំនូវវចនាសម្ព័ន្ធផងដែរ។ កម្រងសំណួរនេះគឺត្រូវបោះពុម្ព ហើយក៏អាច ផ្ញើតាមអ៊ីម៉ែល ឬអនឡាញ ឬសួរដោយផ្ទាល់មាត់តាមទូរសព្ទផងដែរ។ កម្រង សំណួរនេះជាបច្ចេកទេសប្រមូលទិន្នន័យមួយដ៏ពេញនិយមរហូតមកដល់បច្ចុប្បន្ននេះ។ បច្ចេកទេសនេះត្រូវបានប្រើប្រាស់ជាពិសេសក្នុងការប្រមូលទិន្នន័យបែបបរិមាណវិស័យនៅពេលដែលសំណាកមានទំហំធំ។
    - **ការសម្ភាសន៍៖** ការសម្ភាសន៍អាចជួយអ្នកក្នុងការបង្កើនការយល់ដឹងឱ្យបានកាន់ តែស៊ីជម្រៅនៃគំនិតដែលបង្កប់នៅក្នុងចម្លើយរបស់អ្នកឆ្លើយតប។ ការសម្ភាសន៍គឺជាបច្ចេកទេសដ៏ពេញនិយមមួយទៀតក្នុងការស្រាវជ្រាវបែបគុណវិស័យ។
    - **កិច្ចពិភាក្សាក្រុមគោលដៅ៖** កិច្ចពិភាក្សានេះធ្វើឱ្យអន្តរកម្មនៃការសម្ភាសន៍កាន់តែមាន ផលប្រយោជន៍ថែមមួយកម្រិតទៀតតាមរយៈការណែនាំក្រុមដែលបានជ្រើសរើសយ៉ាងយកចិត្តទុកដាក់បំផុតមកធ្វើការពិភាក្សាកម្រិតមធ្យមអំពីកម្មវត្ថុនៃការស្ទង់មតិ។ ជាថ្មីម្តងទៀត កិច្ចពិភាក្សាក្រុមគោលដៅនេះភាគច្រើនប្រើនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ។
    - **ការអង្កេត៖** ការអង្កេតដោយផ្ទាល់អាចជាវិធីសាស្ត្រមួយដ៏ល្អក្នុងការប្រមូលព័ត៌មានដែលមានលក្ខណៈសាមញ្ញៗអំពីកិច្ចការតាមលំដាប់លំដោយដូចជា ការត្រួតពិនិត្យមើលចំនួនកិច្ចអន្តរាគមន៍ដោយផ្ទាល់ ដែលតម្រូវឱ្យយើងធ្វើការមួយថ្ងៃដើម្បីរក្សាដំណើរការ ប្រកបដោយភាពរលូន។ ជារឿយៗការអង្កេតនេះត្រូវបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវ ពីថ្នាក់រៀនទៅលើប្រសិទ្ធភាពនៃបច្ចេកទេសបង្រៀនផ្សេងៗគ្នា។
- ***វិសាលភាពនិងទំហំសំណាក៖*** ចំណុចទាំងពីរនេះគឺអាស្រ័យទៅ លើប្រភេទនៃការស្រាវជ្រាវ របស់យើង ប៉ុន្តែយកល្អត្រូវរក្សាវិសាលភាព និងសំណាកឱ្យតូចល្មម។
- ***ក្របខ័ណ្ឌពេលវេលា៖*** សូមចងចាំថាការស្រាវជ្រាវប្រតិបត្តិគឺគ្រាន់តែជាការសិក្សាសម្រាប់ឱ្យអ្នកស្រាវជ្រាវធ្វើការវាយតម្លៃទៅលើសកម្មភាពរបស់ខ្លួនតែប៉ុណ្ណោះដូចនេះ ត្រូវមានវិសាលភាពតូចល្មម និងរយៈពេលខ្លី។ សមរម្យយោងតាមបទពិសោធន៍កន្លងមក ការស្រាវជ្រាវប្រតិបត្តិ អាចមាន រយៈពេលជាអប្បបរមាចាប់ពី ២ ទៅ ៣ សប្តាហ៍។

## ជំហានទី ២៖ រៀបចំផែនការថវិកា និងផែនការសកម្មភាព

តារាងខាងក្រោមនេះបង្ហាញអំពីរបៀបរៀបចំផែនការថវិកានិងផែនការសកម្មភាពក្នុងករណី ដែលការស្រាវជ្រាវរបស់អ្នកត្រូវការថវិកាដើម្បីគាំទ្រ។ ប្រសិនបើការស្រាវជ្រាវរបស់អ្នកមិនត្រូវការចំណាយនោះទេអ្នកមិនចាំបាច់ប្រើប្រាស់តារាងខាងក្រោមនេះឡើយ។ ឧទាហរណ៍ ជាធម្មតា ការស្រាវជ្រាវលក្ខណៈបុគ្គលម្នាក់ៗ ឬការស្រាវជ្រាវជាក្រុមនៅក្នុងទីតាំងរបស់អ្នកមិនត្រូវការ ចំណាយអ្វីទាំងអស់គឺចំណាយតែពេលវេលាប៉ុណ្ណោះ។

## ទម្រង់ផែនការថវិកា

| # សកម្មភាព | សេចក្ដីពណ៌នា | ឯកតា | #ឯកតា | # ស្រុក | # ថ្ងៃ/យប់ | ថ្លៃចំណាយ | សរុប | ការកែសម្រួល |
|---|---|---|---|---|---|---|---|---|
| ១ | ប្រមូលទិន្នន័យ | | | | | | | |
| | ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ | ម្នាក់ | | | | | | |
| | ការស្នាក់នៅ | ម្នាក់ | | | | | | |
| | ការធ្វើដំណើរ | ម្នាក់ | | | | | | |
| | អាហារសម្រន់ | ម្នាក់ | | | | | | |
| | សម្ភារ | ឯកតា | | | | | | |
| | | | | | សរុបរួម | | | |

## ទម្រង់ផែនការសកម្មភាព

| លរ | សកម្មភាព | ឈ្មោះសាលា / ឈ្មោះទីតាំង | ខេត្ត /ស្រុក | ក្រុមគោលដៅ | ចំនួនថ្ងៃ | កាលបរិច្ឆេទចាប់ផ្ដើម |
|---|---|---|---|---|---|---|
| ១ | កិច្ចប្រជុំធ្វើផែនការស្រាវជ្រាវ | | | | | |
| ២ | ការប្រមូលទិន្នន័យ | | | | | |
| ៣ | ការវិភាគទិន្នន័យ | | | | | |
| ៤ | ការរៀបចំរបាយការណ៍ | | | | | |
| ៥ | សិក្ខាសាលាផ្សព្វផ្សាយ | | | | | |

## ជំហានទី៣៖ ការត្រួតពិនិត្យឯកសារ និងការបង្កើតកម្រងសំណួរ

- ***ការត្រួតពិនិត្យឯកសារ៖*** ការត្រួតពិនិត្យនេះធ្វើឱ្យអ្នកមើលឃើញពីចំណុចបានកើតឡើងពីមុនៗ ហើយថាតើចំណុចណាខ្លះដែលដំណើរការ និងចំណុចដែលខ្វះចន្លោះសម្រាប់អ្នកស្រាវជ្រាវ ដទៃទៀត។ ការត្រួតពិនិត្យនេះត្រូវតែធ្វើឡើងមុនគេដើម្បី៖
  - ☞ មើលពីចំណុចដែលបាន និងមិនបានស៊ើបអង្កេត
  - ☞ កំណត់ប្រភពទិន្នន័យដែលអ្នកស្រាវជ្រាវដទៃទៀតបានប្រើប្រាស់
  - ☞ សិក្សាអំពីរបៀបដែលអ្នកស្រាវជ្រាវដទៃទៀតឱ្យនិយមន័យ និងវាស់វែងគោលគំនិតគន្លឹះ
  - ☞ បង្កើតគម្រោងស្រាវជ្រាវផ្សេងទៀត
  - ☞ ដាក់ការងាររបស់អ្នកចូលទៅក្នុងទស្សនៈ
  - ☞ ផ្ដល់ភស្ដុតាងដែលអាចប្រើប្រាស់សម្រាប់គាំទ្រលទ្ធផលរកឃើញរបស់អ្នក។

កិច្ចការនេះរួមមានឯកសារជាច្រើន ដូចជាឯកសារគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ឬរបាយការណ៍ផ្សេងទៀតដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលត្រួតពិនិត្យឯកសារ ហើយឯកសារទាំងនេះពិតជា មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ផ្ដល់ជាព័ត៌មានអំពីការស៊ើបអង្កេតនាពេលបច្ចុប្បន្ន។ ដ្យាក្រាមខាងក្រោមនេះបង្ហាញអំពីរបៀបត្រួតពិនិត្យឯកសារដើម្បីប្រមូលព័ត៌មានសំខាន់ៗសម្រាប់ការស្រាវជ្រាវ និងជាជំនួយស្មារតីរបស់អ្នក និងការរៀបចំកម្រងសំណួរផងដែរ។




អ្នកអាចរៀបចំត្រួតពិនិត្យឯកសារនេះត្រូវធ្វើតាមវិធីសាស្ត្រជាច្រើន ឧទាហរណ៍ អ្នកអាចផ្តោត ទៅលើការត្រួតពិនិត្យតាមកាលវេលា (ឧទាហរណ : របៀបដែលប្រធានបទនេះត្រូវបានដោះស្រាយពីពេលមួយទៅពេលមួយ)។ ការសរសេរអំពីការត្រួតពិនិត្យឯកសារដ៏ល្អមួយគឺត្រូវចាប់ផ្តើមដោយ បង្ហាញនូវទិដ្ឋភាពធំទូលាយនៃបញ្ហាជុំវិញប្រធានបទ ហើយបន្ទាប់មកបង្រួមបញ្ហាទាំងនោះ ឱ្យទៅជាបញ្ហាកាន់តែជាក់លាក់ដែលពាក់ព័ន្ធកាន់តែជិតស្និទ្ធទៅនឹងសំណួរស្រាវជ្រាវ។

- ***បង្កើតកម្រងសំណួរ៖*** កម្រងសំណួរគឺជាឧបករណ៍ស្រាវជ្រាវមួយដែលមានផ្ទុកនូវសំណួរមួយចំនួនដែលប្រើប្រាស់ក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានពីអ្នកឆ្លើយតប។ ទោះបីជាកម្រងសំណួរត្រូវបានបង្កើតឡើងសម្រាប់ការវិភាគចម្លើយបែបស្ថិតិក៏ដោយ តែវាមិនមែនសម្រាប់តែការវិភាគតែមួយមុខនោះទេ។ កម្រងសំណួរមាន ២ ប្រភេទ៖
  - ☞ **សំណួរបើក** ហៅថាសំណួរមគ្គុទេសក៍ (នាំមុខ) ដោយមិនមានរចនាសម្ព័ន្ធចម្លើយ ហើយជាធម្មតាគឺប្រើប្រាស់នៅក្នុង**ការស្រាវជ្រាវបែបគុណវិស័យ**។ សំណួរបើកគឺជាសំណួរ ដែលត្រូវការចម្លើយលើសពីមួយម៉ាត់ ដែលអាចបង្កើតបានជាបញ្ជី ប្រយោគ កថាខ័ណ្ឌ ឬក៏ ជាសុន្ទរកថា។ សំណួរប្រភេទនេះផ្តល់សេរីភាពឱ្យអ្នកឆ្លើយតបក្នុងការឆ្លើយនូវចម្លើយណាមួយ ក៏បានដែលពួកគេចង់ឆ្លើយ។ ចំនួនសំណួរសម្រាប់កម្រងសំណួរប្រភេទនេះ គឺត្រូវមានសំណួរ យ៉ាងច្រើនបំផុតចន្លោះចាប់ពី ៥ ទៅ ១៥ សំណួរ។
  - ☞ **សំណួរបិទ** គឺប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យនៅក្នុងក្របខ័ណ្ឌជម្រើសមានកំណត់ ហើយការកំណត់នេះគឺជាមូលដ្ឋានគ្រឹះនៃការវិភាគស្ថិតិទាំងអស់ដែលអនុវត្តនៅក្នុង**ការស្រាវជ្រាវបែបបរិមាណវិស័យ**។ សំណួរទាំងអស់នេះត្រូវបានបង្កើតឡើងដោយមានរចនាសម្ព័ន្ធចម្លើយ ហើយអ្នកឆ្លើយតប គឺត្រូវបានកំណត់ក្នុងការផ្តល់ចម្លើយរបស់ពួកគេ ប៉ុន្តែសំណួរប្រភេទនេះ គឺមានភាពពេញនិយមសម្រាប់អ្នកស្រាវជ្រាវដែលថ្មី ដោយសារតែវាមានភាពងាយស្រួលក្នុងការវិភាគដោយប្រើកម្មវិធី Excel ឬ SPSS។ ទោះជាយ៉ាងនេះក្តី ការបង្កើតសំណួរនិង ជម្រើសសម្រាប់ចម្លើយទាំងអស់ គឺត្រូវការជំនាញពិសេស។ ជារឿយៗ សំណួរចន្លោះចាប់ពី ១៥ ទៅ ២៥ សំណួរគឺចាត់ទុកថាមិនមានបញ្ហាអ្វីឡើយនៅក្នុងកម្រងសំណួរបែបបរិមាណវិស័យ។

**តារាងខាងក្រោមបង្ហាញពីភាពខុសគ្នារវាងសំណួរបើក និងសំណួរបិទ៖**

| សំណួរបើកសម្រាប់ការស្រាវជ្រាវបែបគុណវិស័យ | សំណួរបិទសម្រាប់ការស្រាវជ្រាវបែបបរិមាណវិស័យ |
|---|---|
| ១. តើអ្នកចូលចិត្តមុខវិជ្ជាណាខ្លាំងជាងគេបំផុត? ហេតុអ្វី?<br>.............................................................<br>.............................................................<br>.............................................................<br>.............................................................<br>.............................................................<br>.............................................................<br>............................................................. | ១. តើអ្នកចូលចិត្តមុខវិជ្ជាណាខ្លាំងជាងគេបំផុត?<br>ក) គណិតវិទ្យា ☐<br>ខ) គីមីវិទ្យា ☐<br>គ) ជីវវិទ្យា ☐<br>២. ហេតុអ្វីបានជាអ្នកចូលចិត្តមុខវិជ្ជានេះ?<br>ក) ខ្ញុំចូលចិត្តគណនាលេខ ☐<br>ខ) ងាយស្រួលរៀន ☐<br>គ) សប្បាយនៅពេលរៀនមុខវិជ្ជានេះ ☐ |

# ដំណាក់កាលទី ៣ ៖ ការអនុវត្ត

### ជំហានទី ១៖ ការប្រមូលទិន្នន័យ

ការស្រាវជ្រាវប្រតិបត្តិអាចរួមបញ្ចូលវិធីសាស្ត្រនិងបច្ចេកទេសប្រមូលទិន្នន័យគ្រប់ប្រភេទ ដូចជាវិធីសាស្ត្របែបគុណវិស័យ និងបរិមាណវិស័យ រួមមានការសម្ភាសន៍ និងស្ទង់មតិ គឺត្រូវបានប្រើប្រាស់ជាទូទៅ។ ផែនការស្រាវជ្រាវ (ToR) គឺពិតជាមានសារៈសំខាន់ដោយសារតែវារៀបរាប់លម្អិតអំពីវិធីសាស្ត្រនិងបច្ចេកទេសស្រាវជ្រាវ វិសាលភាព និងប្រភេទនៃអ្នកផ្តល់ចម្លើយ។ ដូចនេះ ការប្រមូលទិន្នន័យត្រូវតែអនុវត្តឱ្យស្របតាមការកំណត់របស់ផែនការស្រាវជ្រាវ។ ជាទូទៅ ការប្រមូលទិន្នន័យគឺធ្វើឡើងបន្ទាប់ពីបញ្ចប់ការបង្កើតកម្រងសំណួរ។ យោងតាមការអនុវត្ត ជាក់ស្តែង ការស្រាវជ្រាវបែបគុណវិស័យ គឺទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ជាងការ ស្រាវជ្រាវបែបបរិមាណវិស័យ ដោយសារតែប្រភេទនៃសំណួរ និងបច្ចេកទេសនៃការស្រាវជ្រាវ នេះមានភាពស្មុគស្មាញជាង។ ការប្រមូលទិន្នន័យក្នុងការស្រាវជ្រាវបែបបរិមាណវិស័យ គឺមាន លក្ខណៈសាមញ្ញពោល គឺអាចផ្ញើកម្រងសំណួរជាលាយលក្ខណ៍អក្សរ ដោយមានស្រាប់នូវ រចនាសម្ព័ន្ធចម្លើយ ឬក៏អាចប្រើប្រាស់កម្រងសំណួរនេះសម្រាប់ធ្វើការសម្ភាសន៍ទល់មុខគ្នា ដែលតម្រូវឱ្យមានអ្នកសម្ភាសន៍និងអ្នកផ្តល់ចម្លើយតែប៉ុណ្ណោះ។ ផ្ទុយមកវិញជារឿយៗការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (ការសម្ភាសន៍មួយទល់និងមួយ) និងកិច្ចពិភាក្សាជាក្រុម (FGD) គឺត្រូវបានប្រើប្រាស់នៅក្នុងការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវបែបគុណវិស័យ ដូចនេះ តម្រូវឱ្យមានធនធានបន្ថែមទៀត ដូចជា ចំនួនអ្នកសម្ភាសន៍ច្រើន យ៉ាងហោចណាស់ ២ នាក់ (អ្នកសម្របសម្រួល និងអ្នកកត់ត្រា) ដែលមានជំនាញសម្របសម្រួល និងជំនាញរៀបចំ។ រូបភាពខាងក្រោមនេះណែនាំអ្នកអំពីរបៀបរៀបចំការសម្ភាសន៍មួយទល់ និងកិច្ចពិភាក្សា ជាក្រុមឱ្យបានសមស្រប៖



អ្នកសម្ភាសន៍ និងអ្នកផ្តល់ចម្លើយអង្គុយទល់មុខគ្នា ធ្វើដូច្នេះពួកគេអាចធ្វើអន្តរកម្មទល់មុខគ្នា។ ការសម្ភាសន៍នេះធ្វើឱ្យអ្នកសម្ភាសន៍/អ្នកសម្របសម្រួល អាចអង្កេតមើលអ្នកផ្តល់ចម្លើយក្នុងពេលកំពុងសម្ភាសន៍ ឬដើម្បី ឱ្យអ្នកកត់ត្រា អាចកត់ត្រានូវចំណុចសំខាន់ៗ ដែលអាចប្រើប្រាស់ ជាឯកសារ សម្រាប់ការផ្ទៀងផ្ទាត់នៅក្នុងពហុវិធីសាស្ត្រប្រមូល ទិន្នន័យ។ ជាការល្អ សូមធ្វើឱ្យការសម្ភាសន៍នេះមានលក្ខណៈសាមញ្ញ និងមិនផ្លូវការតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យអ្នកផ្តល់ចម្លើយមាន អារម្មណ៍ងាយស្រួល និងផ្តល់ចម្លើយដោយមិនមានសម្ពាធ។

ការសម្ភាសន៍មួយទល់នឹងមួយ



អ្នកសម្ភាសន៍គួរតែរៀបចំអ្នកចូលរួមឱ្យអង្គុយជារង្វង់នៅពេលប្រជុំម្តងៗ។ កិច្ចពិភាក្សាក្រុមគោលដៅ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាព ក្នុងការប្រមូលទិន្នន័យពីអ្នកឆ្លើយតបគួបផ្សំជាមួយនឹងការរក្សា ក្រសែភ្នែកមើលគ្នា (eye contact) ការប្រាស្រ័យទាក់ទងទល់មុខគ្នា ព្រមទាំងគំនិត និងទស្សនៈជាច្រើនពីអ្នកចូលរួមនៅ ក្នុងកិច្ចប្រជុំ គ្រប់រូបផងដែរ។ លើសពីនេះទៅទៀត អ្នកសម្ភាសន៍អាចកត់សម្គាល់ អ្នកចូលរួមដែលអសកម្មបានយ៉ាងងាយ ហើយលើកទឹកចិត្តឱ្យ ពួកគេកាន់តែសកម្មជាងនេះ។ កិច្ចពិភាក្សាក្រុមគោលដៅទាមទារឱ្យ មានមនុស្ស ២ នាក់ ដោយម្នាក់ធ្វើជាអ្នកសម្របសម្រួល និងម្នាក់ទៀតជាអ្នកកត់ត្រានូវរាល់ចម្លើយ ឬការនិយាយរបស់អ្នកឆ្លើយតប។ ចំនួនស្តង់ដារសម្រាប់អ្នកចូលរួមក្នុងកិច្ចពិភាក្សា ក្រុមគោលដៅ គឺចន្លោះចាប់ពី៤ទៅ៦នាក់។

កិច្ចពិភាក្សាជាក្រុម (FGD)



### ជំហានទី ២៖ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យគឺពិតជាសំខាន់ខ្លាំងណាស់នៅក្នុងវដ្តនៃការស្រាវជ្រាវប្រតិបត្តិ។ ការវិភាគទិន្នន័យត្រូវបានគេឱ្យនិយមន័យថា ជាដំណើរការចាត់ថ្នាក់បំបែង និងបកស្រាយ ទិន្នន័យឱ្យទៅជាព័ត៌មានមានប្រយោជន៍សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគន្លងអាជីព ឬការអនុវត្តគម្រោង។ការវិភាគទិន្នន័យចាប់ផ្តើមពីការដាក់កូដទិន្នន័យ។ ការដាក់កូដគឺជាវិធី សាស្ត្រមួយក្នុងការសម្គាល់ ឬចាត់ថ្នាក់អត្ថបទដើម្បីបង្កើតជាក្របខ័ណ្ឌខ្លឹមសារនៃគំនិត។ ការវិភាគទិន្នន័យមានច្រើនប្រភេទដោយអាស្រ័យទៅលើបច្ចេកវិទ្យា និងនវានុវត្តន៍។ បើទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវប្រតិបត្តិគួរតែជ្រើសរើសយកវិធីសាស្ត្រ ដែលសាមញ្ញបំផុតដើម្បីឱ្យស័ក្តិសមនឹងសមត្ថភាពរបស់អ្នកស្រាវជ្រាវថ្មីនៅក្នុងវិស័យអប់រំ ដោយពឹងផ្អែកលើបរិបទបច្ចុប្បន្នជាមូលដ្ឋាន។ ទាំងនេះគឺជាឧបករណ៍ ២ ដែលសាមញ្ញសម្រាប់ ការវិភាគទិន្នន័យ៖ តារាងម៉ាទ្រិច និងទម្រង់បញ្ចូលទិន្នន័យ។

តារាងម៉ាទ្រិច គឺជាទម្រង់មួយដែលប្រើប្រាស់ដើម្បីបូកសរុប និងវិភាគចម្លើយដែលបានមកពី ការស្រាវជ្រាវបែបគុណវិស័យ ហើយជាធម្មតា តារាងនេះគឺបង្កើតឡើងនៅក្នុងកម្មវិធី MS. Word ឬកម្មវិធី MS. Excel ដើម្បីផ្តល់ជំនួយដល់អ្នកស្រាវជ្រាវក្នុងការបកស្រាយទិន្នន័យ ហើយបន្ទាប់ មកទៀត កត់ត្រាទិន្នន័យដែលបានបកស្រាយរួចនោះ ដាក់ចូលទៅក្នុងរបាយការណ៍។

**សូមមើលតារាងម៉ាទ្រិចគំរូដូចខាងក្រោម៖**

| សំណួរ | គ្រូបង្រៀន | នាយកសាលា | លទ្ធផលរកឃើញសំខាន់ៗ |
| --- | --- | --- | --- |
| តើអ្នកណាជាតួអង្គសំខាន់នៅក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសាលា? | ខ្ញុំគិតថាបុគ្គលិកអប់រំមកពីមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក នាយកសាលា គណនេយ្យកររបស់សាលា។ និយាយឱ្យស្មោះត្រង់ទៅខ្ញុំមិនដែលត្រូវបាននាយកសាលាអញ្ជើញឱ្យរៀបចំ ផែនការប្រតិបត្តិប្រចាំឆ្នាំសាលា។ | យោងតាមការអនុវត្តរបស់ខ្ញុំ មានតែនាយកសាលា នាយករង និងគណនេយ្យកររបស់សាលាទេ ដែលធ្វើការរួមគ្នាដើម្បីរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសាលា ពីព្រោះគ្រូបង្រៀនគឺតែងតែរវល់ជាមួយនឹងការបង្រៀន។ | ផ្អែកលើចម្លើយពីគ្រូបង្រៀន និងនាយកសាលា មានតែតួអង្គ ប៉ុន្មាននាក់ប៉ុណ្ណោះដូចជា នាយកសាលា គណនេយ្យករសាលាបុគ្គលិកមន្ទីរអប់រំខេត្តនិងការិយាល័យ អប់រំស្រុក ចូលរួមនៅក្នុងការរៀបចំ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលា។ ផ្ទុយទៅវិញ គ្រូបង្រៀនគឺមិន ដែលត្រូវបានអញ្ជើញនោះឡើយ ហើយក៏មិន មានការចូលរួមពីសហគមន៍ ឬសិស្សនោះដែរ។ |

**ទម្រង់សម្រាប់បញ្ចូលទិន្នន័យ** គឺជាទម្រង់ដែលបង្កើតឡើង និងប្រើប្រាស់សម្រាប់ការវិភាគ ទិន្នន័យបែបបរិមាណវិស័យដើម្បីបង្កើតលទ្ធផលជាតួលេខ ឬស្ថិតិដើម្បីដាក់បញ្ចូលទៅក្នុង របាយការណ៍ស្រាវជ្រាវ។ ទម្រង់នេះមានគោលដៅពន្យល់ពីបាតុភូត ទស្សនៈ ឥរិយាបថ និងផលវិបាក។ ដើម្បីបង្កើតទម្រង់បញ្ចូលទិន្នន័យ សូមអានសេចក្ដីណែនាំខាងក្រោម៖

ជាដំបូង ត្រូវបង្កើតតារាងនៅក្នុងកម្មវិធី Excel ហើយដាក់ឈ្មោះថា "ទម្រង់បញ្ចូលទិន្នន័យ"។ នៅក្នុង តារាងនេះ បង្កើតជួរឈរដោយផ្អែកលើក ម្រងសំណួរ (ចំនួនសំណួរ)។ ជួរឈរទីមួយគឺទៅតាមចំនួន អ្នក ចូលរួម (ចំនួនអ្នកផ្ដល់ចម្លើយ) ហើយជួរឈរបន្តបន្ទាប់មាននូវសំណួរ។

បន្ទាប់មក បង្កើតតារាងថ្មីមួយទៀត ហើយដាក់ឈ្មោះថា តារាងដាក់កូដ ដែលជាបញ្ជីនៃចម្លើយទាំងអស់សម្រាប់សំណួរនីមួយៗនៅក្នុងកម្រងសំណួរស្រាវជ្រាវ។ ប្រើប្រាស់តារាងនេះដើម្បីដាក់កូដចម្លើយទាំងអស់ដែលទទួលបានពីអ្នកឆ្លើយតប។

ដើម្បីដាក់កូដចម្លើយ សូមជ្រើសរើសជួរដេកនៅក្រោមសំណួរ

- ចុច Data
- Data Validation
- List
- Source
- select Coding Sheet
- ចុច Ok.

បន្ទាប់មកទៀតដាក់កូដគ្រប់ចម្លើយទាំងអស់នៅក្នុងទម្រង់បញ្ចូលទិន្នន័យដោយជ្រើសរើសពាក្យពីក្នុងប្រអប់មីនុយ។

ប្រអប់នៅខាងស្ដាំដៃគឺជាលទ្ធផលដែលបានមកពីការដាក់កូដ។

ដើម្បីរាប់ទិន្នន័យ សូមអានការណែនាំនេះ៖

- បង្កើតតារាងរាប់ទិន្នន័យ
- ជ្រើសរើសជួរដេកនីមួយៗនៅក្រោមលទ្ធផល
- វាយ = បញ្ចូលអនុគមន៍ (fx)
- ជ្រើសរើស COUNTIF
- នៅក្នុងប្រអប់ Range ជ្រើសរើស ទម្រង់បញ្ចូលទិន្នន័យ បន្ទាប់មកដាក់សញ្ញាក្បៀស (,) ហើយជ្រើសរើសតារាងដាក់កូដ (ជ្រើសរើសពាក្យ ឬកូដ ដែលអ្នកចង់រាប់)
- ចុច Ok.

| ទម្រង់បញ្ចូលទិន្នន័យ | | |
|---|---|---|
| លេខរៀងអ្នកចូលរួម | សំណួរទី១ | សំណួរទី២ |
| | តើអ្នកចូលចិត្តមុខវិជ្ជាអ្វីជាងគេបំផុត? | ហេតុអ្វីបានជាអ្នកចូលចិត្តមុខវិជ្ជានេះ? |
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |

| លេខសំណួរ | កូដចម្លើយ |
|---|---|
| ១ | ក) គណិតវិទ្យា |
| | ខ) គីមីវិទ្យា |
| | គ) ជីវវិទ្យា |
| ២ | ក) ខ្ញុំចូលចិត្តគណនាលេខ |
| | ខ) ងាយស្រួលរៀន |
| | គ) សប្បាយនៅពេលរៀនមុខវិជ្ជានេះ |

| ទម្រង់បញ្ចូលទិន្នន័យ | | |
|---|---|---|
| លេខរៀងអ្នកចូលរួម | សំណួរទី១ | សំណួរទី២ |
| | តើអ្នកចូលចិត្តមុខវិជ្ជាអ្វីជាងគេបំផុត? | ហេតុអ្វីបានជាអ្នកចូលចិត្តមុខវិជ្ជានេះ? |
| ១ | ក) គណិតវិទ្យា | ក) ខ្ញុំចូលចិត្តគណនាលេខ |
| ២ | ក) គណិតវិទ្យា | ខ) ងាយស្រួលរៀន |
| ៣ | ខ) គីមីវិទ្យា | គ) សប្បាយនៅពេលរៀនមុខវិជ្ជានេះ |
| ៤ | គ) ជីវវិទ្យា | ខ) ងាយស្រួលរៀន |
| ៥ | ក) គណិតវិទ្យា | ក) ខ្ញុំចូលចិត្តគណនាលេខ |




| រាប់ទិន្នន័យ | | |
|---|---|---|
| លេខសំណួរ | កូដចម្លើយ | លទ្ធផល |
| ១ | ក) គណិតវិទ្យា | ៣ |
| | ខ) គីមីវិទ្យា | ១ |
| | គ) ជីវវិទ្យា | ១ |
| ២ | ក) ខ្ញុំចូលចិត្តគណនាលេខ | ២ |
| | ខ) ងាយស្រួលរៀន | ២ |
| | គ) សប្បាយនៅពេលរៀនមុខវិជ្ជានេះ | ១ |

ការធ្វើដ្យាក្រាមគឺជាដំណាក់កាលចុងក្រោយគេបង្អស់នៅក្នុងការវិភាគទិន្នន័យសម្រាប់ការស្រាវជ្រាវបែបបរិមាណវិស័យ ហើយបន្ទាប់មក យកដ្យាក្រាមនេះដាក់បញ្ចូលក្នុងការសរសេររបាយការណ៍ដើម្បីធ្វើការពន្យល់ និងពណ៌នា។

- ជ្រើសរើសកូដចម្លើយ និងលទ្ធផលនៅក្នុងតារាងរាប់ទិន្នន័យតាមសំណួរនីមួយៗ
- ចុចម៉ៅស៍ស្តាំ
- ជ្រើសរើសពាក្យ Quick Data Analysis
- ជ្រើសរើសដ្យាក្រាមដែលអ្នកចូលចិត្ត
- ចុច Ok.

អ្នកអាចយកដ្យាក្រាមទៅដាក់នៅក្នុងសន្លឹកកិច្ចការថ្មីដោយដាក់ឈ្មោះថា ដ្យាក្រាមលទ្ធផលស្រាវជ្រាវ ដោយចុចម៉ៅស៍ស្តាំនៅលើតារាង

- រើសយកពាក្យ Move chart
- ចុច Object in
- ជ្រើសរើសឈ្មោះនៅក្នុងប្រអប់ (ដ្យាក្រាមលទ្ធផលស្រាវជ្រាវ)







## ជំហានទី ៣៖ ការសរសេររបាយការណ៍

ការសរសេររបាយការណ៍គឺជាជំហានដែលសំខាន់នៅក្នុងដំណើរការស្រាវជ្រាវ។ របាយការណ៍នេះ ពណ៌នាអំពីការងារស្រាវជ្រាវដែលបានធ្វើរួចរាល់ និងរួមបញ្ចូលនូវជំហានមួយចំនួន ទៀតនៅក្នុងការបង្ហាញអំពីលទ្ធផលរកឃើញសំខាន់ៗ/លទ្ធផលស្រាវជ្រាវនៅក្នុងទម្រង់ជាអត្ថបទ ឬនិក្ខេបបទ។ ខាងក្រោមនេះគឺជាគំរូរបាយការណ៍ដែលណែនាំឱ្យប្រើ៖

- ***បញ្ជីអក្សរ/ពាក្យកាត់៖*** គឺជាបញ្ជីនៃអក្សរឬឃ្លាកាត់ឧទាហរណ៍ CDP គឺជាអក្សរកាត់នៃពាក្យ "ភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព"។
- ***សេចក្តីសង្ខេប៖*** ផ្នែកនេះសង្ខេបរបាយការណ៍របស់អ្នកហើយជាធម្មតា សេចក្តីសង្ខេបនេះគឺត្រូវ សរសេរបន្ទាប់ពីគ្រប់ចំណុចទាំងអស់នៅក្នុងរបាយការណ៍ត្រូវបានបញ្ចប់ទាំងស្រុង ឬអាច និយាយម្យ៉ាងទៀតថាសេចក្តីសង្ខេបជារឿយៗសរសេរនៅក្នុងដំណាក់កាលក្រោយគេបង្អស់។
- ***សេចក្តីផ្តើម៖*** ផ្នែកនេះគួរតែសរសេរដោយប្រើគំនិតគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ ហើយសេចក្តីផ្តើមនេះអាចរួមបញ្ចូលនូវប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ប្រជាសាស្ត្រ បញ្ហានៃ ការផាត់ចេញពីសង្គម និងយេនឌ័រ។ ជារឿយៗ សេចក្តីផ្តើមនេះមានមួយទំព័រតែប៉ុណ្ណោះ។

- ***ការកំណត់បញ្ហា៖*** ផ្នែកនេះគឺជាការពណ៌នាអំពីបញ្ហាដោយសង្ខេប ដែលការស្រាវជ្រាវនេះមាន គោលបំណងក្នុងការដោះស្រាយឬជាស្ថានភាពដែលត្រូវកែលម្អ។ ការកំណត់បញ្ហា គួរតែមានការរៀបរាប់លម្អិតអំពីបញ្ហាជាក់លាក់ដែលការស្រាវជ្រាវនេះមានគោលដៅស្វែងរកឱ្យឃើញ។ ជារួមការកំណត់បញ្ហាត្រូវតែមានភាពច្បាស់លាស់ សង្ខេប ប្រាកដនិយម និងពាក់ព័ន្ធនិងបរិបទសង្គម។
- គោលបំណងនៃការស្រាវជ្រាវ៖ គឺជាសម្រង់ដែលស្រង់ចេញពីល័ក្ខខ័ណ្ឌយោង (ToR)។
- សំណួរស្រាវជ្រាវ៖ គឺជាសំណួរដែលប្រើប្រាស់នៅក្នុងការសិក្សាដើម្បីឆ្លើយតបទៅនឹង គោលបំណងនៃការស្រាវជ្រាវ។
- វិធីសាស្ត្រនៃការស្រាវជ្រាវ៖ គឺជាសម្រង់មួយទៀតដែលស្រង់ចេញពីល័ក្ខខ័ណ្ឌយោង (ToR)។
- វិសាលភាព និងសំណាក៖ គឺជាសម្រង់មួយទៀតដែលស្រង់ចេញពីល័ក្ខខ័ណ្ឌយោង (ToR)។
- លទ្ធផលរកឃើញសំខាន់ៗ៖ ផ្នែកនេះគឺជាចំណុចស្នូលនៃរបាយការណ៍ ដោយសារតែ ផ្នែកនេះត្រូវតែរៀបរាប់ឱ្យបានលម្អិតអំពីលទ្ធផលរកឃើញ និងសំយោគព័ត៌មានឱ្យទៅ ជាសេចក្តីពណ៌នានៃលទ្ធផលដោយផ្អែកទៅលើការវិភាគទិន្នន័យរបស់អ្នក។ ជារឿយៗ ផ្នែកនេះមានប្រវែងចាប់ពី ២ ឬ ៣ ទំព័រ។
- ***បញ្ហាប្រឈម៖*** ចំណុចនេះគួរតែរួមបញ្ចូលនូវសេចក្តីសង្ខេបនៃបញ្ហាប្រឈម ឬបញ្ហានានា ដែលក្រុមស្រាវជ្រាវបានជួបប្រទះនៅក្នុងពេលធ្វើការស្រាវជ្រាវចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ការស្រាវជ្រាវនេះ។
- ***បទពិសោធន៍៖*** តើអ្នករៀនសូត្រអ្វីខ្លះពីដំណើរការស្រាវជ្រាវនេះ? ចូររាប់ចំណុចដែល អ្នកបានរៀនសូត្រនៅក្នុងការស្រាវជ្រាវនេះ។
- ***សេចក្តីសន្និដ្ឋាន៖***បូកសរុបនិងសង្ខេបការកំណត់បញ្ហាគោលបំណង និងវិធីសាស្ត្រស្រាវជ្រាវ ព្រមទាំងលទ្ធផលរកឃើញសំខាន់ៗនៅក្នុងសេចក្តីសន្និដ្ឋាននេះ ដោយសរសេរពីរ ឬបីកថាខ័ណ្ឌ ឬប្រយោគ ប៉ុន្តែសូមជៀសវាងសរសេរដោយដាក់ជាចំណុចៗ។
- ***អនុសាសន៍៖*** ផ្នែកអនុសាសន៍គួរតែអាចសម្រេចបាន មានលក្ខណៈ SMART និងអាច សម្របសម្រួលបាន ឬអាចរួមបញ្ចូលនូវការណែនាំសម្រាប់ការសិក្សាបន្ថែមទៀតដោយផ្អែកលើលទ្ធផលរកឃើញដើម្បីដោះស្រាយនូវបញ្ហា។
- ***ឧបសម្ព័ន្ធ៖*** ភ្ជាប់ល័ក្ខខ័ណ្ឌយោង (ToR) របស់អ្នក និងកម្រងសំណួរ ឬក៏ឯកសារយោងផ្សេងៗ ដែលបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវ។

## ជំហានទី ៤៖ សិក្ខាសាលាផ្សព្វផ្សាយលទ្ធផល

សិក្ខាសាលាផ្សព្វផ្សាយលទ្ធផល មានគោលដៅក្នុងការដាក់បញ្ចូលលទ្ធផលរកឃើញសំខាន់ៗ ទៅក្នុងការធ្វើផែនការវិស័យអប់រំសម្រាប់ការកែលម្អឱ្យបានកាន់តែប្រសើរឡើងនាពេលអនាគតជាពិសេសនៅក្នុងការសិក្សា។ សិក្ខាសាលានេះ គួរតែធ្វើឡើងបន្ទាប់ពីបានបញ្ចប់របាយការណ៍ ការស្រាវជ្រាវប្រតិបត្តិ ដើម្បីឱ្យក្រុមស្រាវជ្រាវមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំរបៀបវារៈសមស្រប និងពិធីការ (logistic) ដែលត្រូវការជាចាំបាច់ក្នុងការធានាថាសិក្ខាសាលានេះដំណើរការទៅដោយរលូន និងមានប្រសិទ្ធភាព។ សិក្ខាសាលានេះកំណត់គោលដៅតែទៅលើជនបង្គោលប៉ុណ្ណោះ ដូចជាមន្ត្រីអប់រំដែលចូលរួមនៅក្នុងការបង្កើតផែនការវិស័យអប់រំ និងថ្នាក់ដឹកនាំអង្គភាពពាក់ព័ន្ធនានា។ របៀបវារៈខាងក្រោមនេះគឺជាឧទាហរណ៍មួយដែលអ្នកស្រាវជ្រាវអាចសម្របតាមបរិបទដោយផ្អែកលើបរិបទជាក់ស្តែង។



| ប្រធានបទ | ពេលវេលា |
| --- | --- |
| អ្នកចូលរួមមកដល់ និងចុះឈ្មោះ | ១៥ នាទី |
| ស្វាគមន៍អ្នកចូលរួម បង្ហាញអំពីគោលបំណងចម្បងនៃសិក្ខាសាលា | ១០នាទី |
| ក្រុមស្រាវជ្រាវធ្វើបទបង្ហាញអំពីលទ្ធផលស្រាវជ្រាវប្រតិបត្តិ Action Research (AR)៖<br>• ការកំណត់បញ្ហា<br>• គោលបំណងនៃការសិក្សា<br>• វិធីសាស្ត្រស្រាវជ្រាវ<br>• វិសាលភាព និងសំណាក<br>• លទ្ធផលរកឃើញសំខាន់ៗ<br>• បញ្ហាប្រឈម<br>• បទពិសោធន៍<br>• សេចក្តីសន្និដ្ឋាន<br>• អនុសាសន | ១២០ នាទី |
| សម្រាកញ៉ាំអាហារសម្រន់ | ១៥ នាទី |
| សំណួរ និងចម្លើយ | ១០ នាទី |
| បែងចែកក្រុមធំទៅជាក្រុមតូចៗដើម្បីពិភាក្សាជ្រើសរើសលទ្ធផលរកឃើញសំខាន់ជាអាទិភាព និងអនុសាសន៍ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំនៅកម្រិតសាលារៀន ថ្នាក់ស្រុក និងខេត្ត។ | ១ ម៉ោង |
| សុន្ទរកថាបញ្ចប់ | ១០ នាទី |



# ដំណាក់កាលទី ៤ ៖ ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងការវាយតម្លៃគឺជាដំណើរការមួយដែលអ្នកស្រាវជ្រាវចំណាយពេល ដើម្បីធ្វើការពិចារណាថ្លឹងថ្លែង និងការវាយតម្លៃទៅលើប្រសិទ្ធភាពនៃការស្រាវជ្រាវ និងសកម្មភាព ដែលបានអនុវត្តបន្ទាប់ពីបានដាក់បញ្ចូលលទ្ធផលរកឃើញសំខាន់ៗ ទៅក្នុងផែនការរបស់ខ្លួនរួច។ ចំណុចនេះមានន័យថា ពួកគេធ្វើការវាយតម្លៃទៅលើភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនៃការ សិក្សាស្រាវជ្រាវ ហើយឆ្លុះបញ្ចាំងអំពីរបៀបដែលត្រូវកែលម្អនៅពេលដែលពួកគេបានធ្វើការ ស្រាវជ្រាវមួយទៀតនៅពេលអនាគត ក៏ដូចជាប្រសិទ្ធភាពនៃលទ្ធផលរកឃើញសំខាន់ៗ ឬ ដាក់បញ្ចូលលទ្ធផលរកឃើញទាំងនេះទៅក្នុងផែនការសកម្មភាពវិស័យអប់រំ។ស្របពេលជាមួយគ្នានេះដែរអ្នកដឹកនាំតម្រង់ទិសការស្រាវជ្រាវត្រូវមានចក្ខុវិស័យដែលនាំផ្លូវ ការងាររបស់ពួកគេក្នុងការប្រមូល និងវិភាគទិន្នន័យដើម្បីទទួលបានព័ត៌មានកាន់តែច្បាស់លាស់ សម្រាប់ធ្វើសម្រេចចិត្តឱ្យកាន់តែប្រសើរឡើង។ អ្នកដឹកនាំតម្រង់ទិសការស្រាវជ្រាវ គឺចូលរួមនៅក្នុងការស្វ័យសិក្សាជាបន្តបន្ទាប់ ដែលពួកគេវាយតម្លៃអំពីតម្រូវការរបស់សាលារៀន កំណត់ចំណុចដែលជួបបញ្ហា និងបង្កើតយុទ្ធសាស្ត្រដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព ហើយបន្ទាប់ មកពួកគេអាចអនុវត្តដំណើរការស្រាវជ្រាវនេះម្តងទៀត។

ការមានផែនការល្អ អាចជួយឱ្យយើងអាចប្រមើលមើលកាន់តែច្បាស់អំពីរបៀបសម្រេចបាននូវ គោលដៅ ចំណែកឯការតាមដាន និងការវាយតម្លៃល្អ ជួយឱ្យយើងរៀនបានកាន់តែច្រើនបន្ថែម ទៀត អំពីចំណុចដែលដំណើរការបានល្អនិងចំណុចនៅខ្វះចន្លោះ ហើយចំណុចទាំងនេះ នឹងក្លាយជាព័ត៌មានសម្រាប់អ្នកអនុវត្តឬអ្នកធ្វើសេចក្តីសម្រេចចិត្តដើម្បីកែលម្អចំណុចអវិជ្ជមាន និងផ្តួចផ្តើមគំនិតថ្មីៗដើម្បីបង្កើនលទ្ធផលដ៏ល្អប្រសើរ។ ការពិនិត្យតាមដានគឺជាដំណើរការ ប្រមូលទិន្នន័យឬព័ត៌មានដើម្បីត្រួតពិនិត្យមើលទៅលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាព។ ឧទាហរណ៍ សកម្មភាពមួយនៅក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសាលារៀន S-AOP បានលើកឡើងថា សិស្សក្រីក្រចំនួន ៥០ នាក់ បានទទួលពានរង្វាន់សិស្សពូកែ ដែលក្នុងម្នាក់ទទួលបានសម្ភារសិក្សា (ប៊ិច ៥ ដើម សៀវភៅសរសេរ ១០ ក្បាល និងកាបូបមួយ) ជារៀងរាល់ឆ្នាំ ដោយមានសិស្សស្រីយ៉ាងតិចបំផុត ៥០% ដូចនេះដំណើរការតាមដាន ត្រូវតែធ្វើការតាមដានទៅលើសិស្សក្រីក្រចំនួន ៥០ នាក់ ដោយមានរាប់បញ្ចូលសិស្សស្រីផងដែរ ដើម្បីដឹងអំពីភាគរយនៃសិស្សស្រី ដើម្បីសម្រេចបាននូវសូចនាករ ហើយដំណើរការនេះហៅថា ការវាយតម្លៃ។ សរុបរួមការពិនិត្យតាមដាននិងការវាយតម្លៃគឺដើម្បីធ្វើការពិនិត្យតាមដានចំនួន និងវាស់វែងទៅលើលទ្ធផលដោយផ្អែកលើសូចនាករនានានៅក្នុងផែនការ។

# ជំពូក ៣៖
# សេចក្តីសន្និដ្ឋាន

សរុបជារួម ការស្រាវជ្រាវប្រតិបត្តិ គឺជាដំណើរការនៃការវិភាគសកម្មភាពរបស់បុគ្គលម្នាក់ និងចែករំលែកលទ្ធផលរកឃើញជាមួយនឹងសហគមន៍ អ្នកទទួលបន្ទុក អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចជា ភាគីពាក់ព័ន្ធផ្សេងទៀតផងដែរ ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះ យោបល់ដើម្បីធ្វើការកែលម្អ និងការអភិវឌ្ឍ។ ការស្រាវជ្រាវនេះអាចធ្វើឡើងតាមរបៀបជាច្រើន ដូចជា នៅក្នុងការងារប្រចាំថ្ងៃ កិច្ចប្រជុំផ្លូវការ និងកិច្ចក្រៅផ្លូវការ ឬនៅក្នុងអង្គសិក្ខាសាលា។

➢ **ចំណុចសម្គាល់ពិសេសនៅក្នុងដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ៖**

ខាងក្រោមនេះគឺជាមតិយោបល់មួយចំនួនអំពីអ្វីដែលត្រូវធ្វើនៅពេលចាប់ផ្តើមធ្វើការស្រាវជ្រាវប្រតិបត្តិរបស់អ្នក៖

- ***រក្សាវិសាលភាពឱ្យតូចល្មម៖*** ការសិក្សានេះគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពរួមដើម្បីមានភាពច្បាស់លាស់អំពីអ្វីដែលអ្នកកំពុងធ្វើការស៊ើបអង្កេតជានិច្ច។ សូមកុំព្យាយាមស៊ើបអង្កេតចំណុចទាំងអស់ ក្នុងពេលតែមួយ ហើយត្រូវកំណត់គោលដៅឱ្យចំផ្ទៃកណាមួយដែលអ្នកចាប់អារម្មណ៍ ក្នុងការស្វែងរក។
- ***ធ្វើផែនការដោយយកចិត្តទុកដាក់៖*** មានន័យថាការកំណត់គោលដៅធំទូលាយពីចំណុចដែលអ្នកសង្ឃឹមថាការស្រាវជ្រាវនឹងនាំ អ្នករកឱ្យឃើញ ប៉ុន្តែមិនមានន័យថាជាការកំណត់គោលបំណងជាក់លាក់នោះទេ។
- ***រៀបចំក្រុមឱ្យបានសមល្មម៖*** មានន័យថាអ្នកស្រាវជ្រាវត្រូវតែបង្កើតរចនាសម្ព័ន្ធក្រុម ដោយមាន តួនាទី និងទំនួលខុសត្រូវច្បាស់លាស់ ព្រមទាំងគួរតែមានតុល្យភាពយេនឌ័រផងដែរ ពីព្រោះថា ប្រសិនបើការរៀបចំក្រុមមិនបានល្អទេនោះ ដំណើរការស្រាវជ្រាវក៏មិនអាចដំណើរការទៅមុខ បានរលូនឡើយ ហើយក៏មិនទទួលបានលទ្ធផលដ៏មានប្រសិទ្ធភាពផងដែរ។
- ***កំណត់រយៈពេលឱ្យបានច្បាស់លាស់៖*** គម្រោងជាក់លាក់ដែលអ្នកកំពុងតែអនុវត្ត នៅក្នុង រយៈពេលខ្លីល្មមនិងគោរពតាមពេលវេលា ដូចនេះអ្នកត្រូវកំណត់ពេលវេលាឱ្យបានសមស្រប។
- ***ផ្តោតការយកចិត្តទុកលើការរៀនសូត្រ៖*** ការស្រាវជ្រាវអាចព្យាយាមផ្តោតការយកចិត្តទុកដាក់ តែទៅលើសកម្មភាព និងធ្វើរបាយការណ៍ដែលផ្តល់នូវការពណ៌នាអំពីសកម្មភាព ពោលគឺ សកម្មភាពដែលអ្នកបានធ្វើ។ ប៉ុន្តែព្យាយាមផ្តោតការយកចិត្តទុកដាក់ទៅលើអ្វីដែលអ្នក បានរៀនពីដំណើរការស្រាវជ្រាវ និងចំណុចដែលនឹងត្រូវផ្លាស់ប្តូរ។

# ឧបសម្ព័ន្ធ ១៖ ទម្រង់របាយការណ៍គំរូ

## ទំព័រមុខ

(ការស្រាវជ្រាវប្រតិបត្តិ)
ប្រធានបទស្រាវជ្រាវ៖

ប្រធានបទស្រាវជ្រាវ

ឈ្មោះខេត្ត/ស្រុក

សមាជិកក្រុម៖

១/ .................................. តួនាទី ..................................
២/ .................................. តួនាទី ..................................
៣/ .................................. តួនាទី ..................................
៤/ .................................. តួនាទី ..................................
៥/ .................................. តួនាទី ..................................
៦/ .................................. តួនាទី ..................................
៧/ .................................. តួនាទី ..................................
៨/ .................................. តួនាទី ..................................
៩/ .................................. តួនាទី ..................................
១០/ .................................. តួនាទី ..................................

## បញ្ជីអក្សរ/ពាក្យកាត់

## មាតិកា


បញ្ជីអក្សរកាត់ ....... 1

i. សេចក្ដីសង្ខេប ........ 2
ii. សេចក្ដីផ្ដើម ........ 3
iii. សេចក្ដីថ្លែងអំពីបញ្ហា ........ 4
iv. គោលបំណងនៃការស្រាវជ្រាវ ........ 5
v. សំណួរស្រាវជ្រាវ ........ 5
vi. វិធីសាស្ត្រស្រាវជ្រាវ ........ 5
vii. វិសាលភាព និងសំណាកគំរូ ........ 6
viii. លទ្ធផលរកឃើញសំខាន់ៗ ........ 7
ix. បញ្ហាប្រឈម........ 8
x. បទពិសោធន៍........ 9
xi. សេចក្ដីសន្និដ្ឋាន ........ 10


i. សេចក្ដីសង្ខេប........

ii. សេចក្ដីផ្ដើម........

iii. សេចក្ដីថ្លែងអំពីបញ្ហា........

iv. គោលបំណងនៃការស្រាវជ្រាវ........

v. សំណួរស្រាវជ្រាវ........

vi. វិធីសាស្ត្រស្រាវជ្រាវ........

vii. វិសាលភាព និងសំណាកគំរូ........

viii. លទ្ធផលរកឃើញសំខាន់ៗ........

ix. បញ្ហាប្រឈម........

x. បទពិសោធន៍........

xi. សេចក្ដីសន្និដ្ឋាន........

xii. អនុសាសន៍........

ឧបសម្ព័ន្ធ I៖ លក្ខខណ្ឌយោង........

ឧបសម្ព័ន្ធ II៖ កម្រងសំណួរ........

# ឯកសារយោង


- https://en.wikipedia.org/wiki/Action_research
- http://www.ascd.org/publications/books/100047/chapters/What-Is-Action-Research%C2%A2.aspx
- https://www.edglossary.org/action-research/
- https://www.researchgate.net/publication/242456051_Action_Research_A_Guide_for_the_Teacher_Researcher
- https://scholarcommons.usf.edu/jpr/vol1/iss1/3/
- https://www.researchgate.net/publication/262140916_Wilcox_K_C_Jeffery_J_2014_

ផ្ទះលេខ១៧ ផ្លូវ២៣៤ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ ០២៣ ៨៨២ ៧៦៨
វើបសាយៈ vsointernational.org